# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA

*Kingdom of Wonder*

**ក្រសួងទេសចរណ៍**

លេខ ៣៧០៧.ឧ៩៣.សចប

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០១៦

## សេចក្តីជូនដំណឹង

## ស្តីពី

## ការអនុវត្តតម្លៃបណ្ណថ្មី សម្រាប់ចូលទស្សនារមណីយដ្ឋានអង្គរ

ក្រសួងទេសចរណ៍មានកិត្តិយសសូមគោរពជម្រាបជូន សាធារណជន ជាតិ អន្តរជាតិ គ្រប់ប្រតិបត្តិករទេសចរណ៍ ព្រមទាំងភ្ញៀវទេសចរបរទេសទាំងអស់មេត្តាជ្រាបថា ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ រាជរដ្ឋាភិបាលនឹងធ្វើការកែប្រែតម្លៃបណ្ណសម្រាប់ភ្ញៀវបរទេសចូលទស្សនារមណីយដ្ឋានអង្គរ ដូចខាងក្រោម៖

- -ប្រភេទបណ្ណចូលទស្សនា ១ថ្ងៃ មានតម្លៃ ៣៧ដុល្លារ
- -ប្រភេទបណ្ណចូលទស្សនា ៣ថ្ងៃ មានតម្លៃ ៦២ដុល្លារ និងមានសុពលភាព១០ថ្ងៃ
- -ប្រភេទបណ្ណចូលទស្សនា ៧ថ្ងៃ មានតម្លៃ ៧២ដុល្លារ និងមានសុពលភាព០១ខែ

នៅក្នុងតម្លៃថ្មីរបស់បណ្ណទាំង៣ប្រភេទខាងលើនេះ គឺចំនួន០២ដុល្លារ សម្រាប់ចូលមូលនិធិមន្ទីរពេទ្យគន្ធបុប្ផាក្នុងការព្យាបាលជំងឺដល់កុមារក្រីក្រកម្ពុជា ។ ចំនួន ០២ដុល្លារនេះ ក៏មានបញ្ជាក់ជាអក្សរនៅលើបណ្ណចូលទស្សនារមណីយដ្ឋានអង្គរ ពីការរួមចំណែកដោយផ្ទាល់ពីភ្ញៀវទេសចរបរទេសក្នុងការចូលរួមជួយព្យាបាលជំងឺដល់កុមារក្រីក្រកម្ពុជាផងដែរ ។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមសាធារណជន ជាតិ អន្តរជាតិ គ្រប់ប្រតិបត្តិករទេសចរណ៍ ព្រមទាំងភ្ញៀវទេសចរបរទេសទាំងអស់ មេត្តាជ្រាប និងត្រៀមរៀបចំ ដើម្បីអនុវត្តតម្លៃបណ្ណថ្មីនេះទៅតាមកាលបរិច្ឆេទដូចបានជម្រាបជូនខាងលើ ។

**ក្រសួងទេសចរណ៍**

អគារលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.mot.kh